2022
FEBRUARY

# ព្រឹត្តិបត្រពាណិជ្ជកម្ម
# iTrade Bulletin

## INSIDE

Local | Global News Brief
Opinion Paper

វ៉ុល១ លេខ០២ - Vol 01 Issue 02

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

កុម្ភៈ ២០២២ - February 2022
វ៉ុល១ លេខ០២ - Vol 01 Issue 02

ព្រឹត្តិបត្រពាណិជ្ជកម្ម
iTrade Bulletin

# ព័ត៌មានក្នុងស្រុក*

## តើកម្ពុជា និងសមាជិកផ្សេងទៀតទទួលបានអ្វីខ្លះពីកិច្ចព្រមព្រៀងអាសិប?

ប្រភព៖ ធនាគារពិភពលោក

កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (អាសិប) ដែលមានសមាជិក ១៥ ប្រទេស និងជាកិច្ចព្រមព្រៀងដែលធំបំផុតលើលោក បានចូលជាធរមាននៅថ្ងៃទី ០១ ខែមករា ឆ្នាំ២០២២។ ក្រោយកិច្ចព្រមព្រៀងនេះចូលជាធរមាន ការសិក្សាមួយចំនួនបានបង្ហាញពីផលប្រយោជន៍ដែលសមាជិកនឹងទទួលបាន រួមទាំងកម្ពុជា។ យោងតាមរបាយការណ៍របស់ធនាគារពិភពលោក បោះពុម្ពផ្សាយក្នុងខែកុម្ភៈ ឆ្នាំ២០២២ សេរីភាវូបនីយកម្មពន្ធគយនៃកិច្ចព្រមព្រៀងនេះ អាចនឹងផ្តល់កំណើនចំណូលពិតប្រមាណ ០,២១ ភាគរយនៅឆ្នាំ២០៣៥។ សេរីភាវូបនីយកម្មវិធានប្រភពដើមទំនិញនឹងផ្តល់កំណើនចំណូលពិតប្រមាណ ០,៤៩ ភាគរយ ខណៈដែលការទទួលបានពីផលិតភាព នឹងផ្តល់កំណើនចំណូលពិតប្រមាណ ២,៥ ភាគរយសម្រាប់សមាជិកជារួមនៃកិច្ចព្រមព្រៀងនេះ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ ពាណិជ្ជកម្មរវាងសមាជិកអាសិប នឹងកើនឡើងប្រមាណ ១២,៣ ភាគរយក្នុងឆ្នាំ២០៣៥។ កិច្ចព្រមព្រៀងនេះក៏អាចជួយប្រជាជនប្រមាណ ២៧ លាននាក់ សម្រេចបានឋានៈជីវភាពកម្រិតមធ្យមនៅឆ្នាំដូចគ្នា។ របាយការណ៍នេះបង្ហាញផងដែរថា កិច្ចព្រមព្រៀងនេះនឹងផ្តល់កំណើននាំចេញរបស់កម្ពុជាប្រមាណ ៦,៥ ភាគរយ ដែលក្នុងនោះ ផលិតផលឈើ និងក្រដាសកើន ៣៤,៨ ភាគរយ, ផលិតផលគីមី កៅស៊ូ និងផ្លាស្ទិកកើន ២៥,៣ ភាគរយ, និងសម្ភារអគ្គិសនី និងគ្រឿងម៉ាស៊ីនកើន ២៤,២ ភាគរយ កើតចេញពីការកាត់បន្ថយពន្ធគយ និងរបាំងមិនមែនពន្ធគយ។ ចុចទីនេះដើម្បីអានរបាយការណ៍

## អង្គរព្រះវិហារ ជាម៉ាកសមូហភាពមួយទៀតត្រូវបានចុះបញ្ជីទុកជាទ្រព្យកម្មសិទ្ធិបញ្ញារួម

ប្រភព៖ ក្រសួងពាណិជ្ជកម្ម

កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ ក្រសួងពាណិជ្ជកម្ម បានសម្ពោធឱ្យប្រើប្រាស់ជាផ្លូវការនូវម៉ាកសមូហភាព **អង្គរព្រះវិហារ** របស់សហភាពសហគមន៍កសិកម្មព្រះវិហារមានជ័យ។ គោលបំណងនៃការចុះបញ្ជីម៉ាកសមូហភាព **អង្គរព្រះវិហារ** គឺដើម្បី៖ (១) ផ្តល់កិច្ចការពារកម្មសិទ្ធិបញ្ញា ដល់សហភាពសហគមន៍កសិកម្មព្រះវិហារមានជ័យ ដែលជាម្ចាស់ម៉ាកសមូហភាព ក្រោមច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងដើម្បីទប់ស្កាត់ការក្លែងបន្លំម៉ាកសមូហភាព **អង្គរព្រះវិហារ** នៅលើទីផ្សារជាតិ និងអន្តរជាតិ (២) អភិរក្សចំណេះដឹង-ចំណេះធ្វើតាមបែបប្រពៃណីរបស់ប្រជាកសិករក្នុងខេត្តព្រះវិហារ តាមរយៈការរៀបចំចងក្រងបទបញ្ជារួមគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព **អង្គរព្រះវិហារ** ...។ ចុចទីនេះដើម្បីអានបន្ថែម

## កម្ពុជា និងកាណាដា ប្តេជ្ញាពង្រឹងទំនាក់ទំនងវិនិយោគ

ប្រភព៖ សារព័ត៌មាន ខ្មែរថាមស៍

ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម មានប្រសាសន៍ថា ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងកាណាដា មានការកើនឡើងគួរឱ្យកត់សម្គាល់ ដែលឆ្លុះបញ្ចាំងតាមរយៈការនាំចេញរបស់កម្ពុជាទៅកាន់ប្រទេសកាណាដា ក្រោមកម្មវិធីអនុគ្រោះពន្ធ និងគ្មានកូតា ដែលមានតម្លៃ ៩៥៤,៨២ លានដុល្លារអាម៉េរិកនៅឆ្នាំ ២០២២។ ឯកឧត្តម ក៏បានស្នើការគាំទ្រពីលោកជំទាវ សារ៉ា ថាយល័រ ឯកអគ្គរដ្ឋទូតកាណាដាប្រចាំកម្ពុជា ដើម្បីសិក្សាអំពីលទ្ធភាពនៃការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-កាណាដា។ លោកជំទាវ បានសន្យាថា កាណាដានឹងជំរុញការចរចាពាណិជ្ជកម្មសេរីអាស៊ាន-

---

* បកប្រែក្រៅផ្លូវការ

កាណាដា បន្ទាប់មកនិងពិនិត្យការសិក្សាពីលទ្ធភាពនៃការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-កាណាដា ស្របតាមគោលនយោបាយពាណិជ្ជកម្ម។ ឯកឧត្តមរដ្ឋមន្ត្រីបានសម្តែងការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ តាមរយៈការលើកកម្ពស់បរិយាកាសធុរកិច្ចនៅកម្ពុជា ជាពិសេសជួយសម្រួលដល់ធុរកិច្ច កាណាដាដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសនេះ។ ចុចទីនេះដើម្បីអានបន្ថែម

## LOCAL NEWS BRIEF

### What Cambodia and Other Members Gain from RCEP?

Source: World Bank

The world's largest trade pact, Regional Comprehensive Economic Partnership (RCEP), consisting of 15 countries has come into force since January 01, 2022. Consequently, some studies have examined how much this trade pact can deliver to its members including Cambodia. According to a World Bank report published in February 2022, the tariff liberalization alone brings an estimated real income gain by 0.21 percent relative to the baseline (without the RCEP) in 2035. With liberal rules of origin, the gains in real income could double to 0.49 percent and the productivity gains would increase the real income by as much as 2.5 percent for the trade bloc. More interestingly, trade among RCEP members would increase by 12.3 percent in 2035 relative to the baseline. The RCEP also has the potential to lift 27 million additional people to middle-class status by the same year. As regards the Cambodia's gains, the report reveals that the pact would expand Cambodia's exports by 6.5 percent, with wood and paper products expanding by 34.8 percent, chemical, rubber, and plastics by 25.3 percent, and electrical equipment, and machinery by 24.2 percent, as the result of tariff and non-tariff measure reduction. Click here to read full report

### Preah Vihear Rice Registered as Another Collective Mark

Source: Ministry of Commerce

The Ministry of Commerce on February 21, 2022 officially launched the effect of the registered collective mark of Preah Vihear Rice of the Preah Vihear Meanchey Agricultural Union Community. The registration of this collective mark aims to (1) provide legal protection of intellectual property rights of the Union Community whose collective mark ownership is provided under the Law concerning Marks, Trade Names, and Acts of Unfair Competition and to prevent the counterfeit of Preah Vihear Rice collective mark in local and global markets, (2) preserve the traditional knowledge and know-how of producers in Preah Vihear province through the issuance of common regulations governing the use of Preah Vihear Rice collective mark ... . Click here to read more

### Cambodia and Canada Agree to Further Strengthen Investment Ties

Source: Khmer Times

Bilateral trade between Cambodia and Canada has seen a significant increase as reflected through Cambodia's export to Canada under a tariff-free and quota-free programme worth $954.82 million by 2022, said Pan Sorasak, Minister of Commerce. The Minister also sought the Ambassador's assistance to conduct a feasibility study on the possibility of establishing a Cambodia-Canada Bilateral Free Trade Agreement. Sarah Taylor, Canadian Ambassador to Cambodia, has assured Canada would promote the ASEAN-Canada Free Trade negotiations and examine the feasibility studies on the possibility of establishing a Cambodia-Canada Bilateral Free Trade Agreement in line with the trade policy. The Cambodian commerce minister expressed Cambodia's commitment to enhancing cooperation between the two countries in promoting a better business environment in Cambodia, especially to facilitate Canadian businesses operating in this country. Click here to read more

# ព័ត៌មានសកល

## អង្គការពាណិជ្ជកម្មពិភពលោក សម្រេចឱ្យចិនឈ្នះក្តីអាម៉េរិកក្នុងករណីជម្លោះពន្ធពាណិជ្ជកម្ម

ប្រភព៖ The Wall Street Journal

អង្គការពាណិជ្ជកម្មពិភពលោក បានអនុញ្ញាតឱ្យចិនដាក់ពន្ធតបតលើទំនិញនាំចូលពីសហរដ្ឋអាម៉េរិក ក្នុងតម្លៃ ៦៤៥ លានដុល្លារ ជុំវិញជម្លោះដែលចិនបានផ្តល់ឧបត្ថម្ភធនដើម្បីជំរុញការនាំចេញទំនិញ ដូចជាបន្ទះសូឡា និងបំពង់ដែកថែបជាដើម។ លោក អាដាម ហជហ្គ៍ អ្នកនាំពាក្យការិយាល័យតំណាងពាណិជ្ជកម្មអាម៉េរិក បានសំដែងនូវការខកចិត្តចំពោះសេចក្តីសម្រេចនេះ ដោយបានលើកឡើងថា អង្គការពាណិជ្ជកម្មពិភពលោក ការពារ "ការអនុវត្តសេដ្ឋកិច្ចមិនមែនទីផ្សាររបស់ចិន និងធ្វើឱ្យប៉ះពាល់ដល់ការប្រកួតប្រជែងតាមបែបទីផ្សារសេរី"។ លោក ឆាត បោន អ្នកស្រាវជ្រាវជាន់ខ្ពស់នៃវិទ្យាស្ថានផេតឺសុនសម្រាប់សេដ្ឋកិច្ចអន្តរជាតិ បានលើកឡើងថា ប្រសិនបើប្រទេសចិនជ្រើសរើសការដាក់ពន្ធតបតតាមការសម្រេចរបស់អង្គការពាណិជ្ជកម្មពិភពលោក នោះនឹងធ្វើឱ្យមានហានិភ័យដល់ការអនុវត្តឡើងវិញនូវការដំឡើងពន្ធក្នុងជម្លោះពាណិជ្ជកម្មអាម៉េរិក-ចិន ដែលមកទល់ពេលនេះនៅមានលក្ខណៈផុយស្រួយនៅឡើយ។ សហរដ្ឋអាម៉េរិក និងបណ្តាប្រទេសសេដ្ឋកិច្ចទីផ្សារសេរីផ្សេងទៀត បានលើកឡើងនូវការមិនពេញចិត្ត ដែលទីក្រុងប៉េកាំងបានផ្តល់អត្ថប្រយោជន៍មិនស្មើគ្នាទៅឱ្យក្រុមហ៊ុនផលិតរបស់ជនជាតិចិន ជាងក្រុមហ៊ុនរបស់ពួកគេ។ តាមការលើកឡើងរបស់លោក ឆាត បោន ការសម្រេចចិត្តចុងក្រោយដែលគាំទ្រប្រទេសចិននេះ គឺជាការ "លើកទឹកចិត្តឱ្យសហរដ្ឋអាម៉េរិក ប្រទេសចិន សហគមន៍អឺរ៉ុប និងបណ្តាប្រទេសធំៗដែលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ត្រូវធ្វើការពិនិត្យរកវិធានថ្មីៗលើបញ្ហាពន្ធតបត"។ ចុចទីនេះដើម្បីអានបន្ថែម

## ក្រុមតស៊ូមតិលើបញ្ហាវ៉ាក់សាំងកំពុងដាក់សម្ពាធលើប្រធានាធិបតីអាមេរិក ឱ្យជួយដោះស្រាយភាពជាប់គាំងនៅអង្គការ WTO

ប្រភព៖ Politico

ក្នុងលិខិតផ្ញើទៅលោក ចូ បៃដិន កន្លងទៅ ក្រុមតស៊ូមតិលើបញ្ហាវ៉ាក់សាំង រួមទាំងអង្គការអហ្វាមអាម៉េរិក បាននិងកំពុងដាក់សម្ពាធលើប្រធានាធិបតីអាម៉េរិក ឱ្យជួយដោះស្រាយវិបត្តិជាប់គាំងនៅអង្គការ WTO តាមរយៈការទទួលយកការទាមទាររបស់ប្រទេសអាហ្វ្រិកខាងត្បូង និងឥណ្ឌា ក្នុងការលើកលែងការការពារសិទ្ធិកម្មសិទ្ធិបញ្ញា សម្រាប់ផលិតផលវ៉ាក់សាំង ដើម្បីប្រយុទ្ធប្រឆាំងជម្ងឺកូវីដ-១៩ ។ កាលពីខែឧសភាឆ្នាំទៅ សហរដ្ឋអាម៉េរិក បានគាំទ្រសំណើររបស់ប្រទេសទាំងពីរនេះ ដែលបន្តទាមទារឱ្យមានការលើកលែងលើកិច្ចការពារកម្មសិទ្ធិបញ្ញាសម្រាប់តែផលិតផលវ៉ាក់សាំងប៉ុណ្ណោះ។ យ៉ាងណាក៏ដោយ សហភាពអឺរ៉ុបនៅតែបន្តជំទាស់នឹងសំណើនេះ ដោយលើកហេតុផលថា ច្បាប់របស់អង្គការ WTO បានអនុញ្ញាតឱ្យប្រទេសនានា លើកលែងការការពារកម្មសិទ្ធិបញ្ញានៅក្នុងគ្រាអាសន្នផ្នែកសុខភាព រួចហើយ។ ក្រុមហ៊ុនឱសថជាច្រើនក៏ប្រឆាំងនឹងសំណើនេះ ដោយលើកហេតុផលថា សំណើបែបនេះនឹងធ្វើឱ្យខូចដល់ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ ហើយនិងមិនជំរុញឱ្យពួកគេវិនិយោគច្រើនក្នុងការអភិវឌ្ឍឱសថសង្គ្រោះជីវិត។ ចុចទីនេះដើម្បីអានបន្ថែម

## សហរដ្ឋអាម៉េរិកឈានទៅបង្កើតក្របខ័ណ្ឌពាណិជ្ជកម្មថ្មីជាមួយតំបន់ឥណ្ឌូប៉ាស៊ីហ្វិក

ប្រភព៖ VOA

រដ្ឋបាលថ្មីរបស់សហរដ្ឋអាម៉េរិក ត្រូវបានគេរំពឹងថានឹងបង្កើតក្របខ័ណ្ឌសេដ្ឋកិច្ចឥណ្ឌូប៉ាស៊ីហ្វិក ដើម្បីទប់ទល់ជាមួយប្រទេសចិន និងដើរជាតួអង្គសំខាន់ ក្នុងការអភិវឌ្ឍវិធានពាណិជ្ជកម្មសម្រាប់គ្រប់គ្រងតំបន់នេះ។ ក្រុមធុរជន និងពាណិជ្ជករអាម៉េរិកមានការបារម្ភ ចំពោះវត្តមានរបស់អាម៉េរិកក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក បន្ទាប់ពីអាម៉េរិក ក្នុងរដ្ឋបាល លោក ដូណាល់ត្រាំ បានដកខ្លួនជាផ្លូវការចេញពីកិច្ចព្រមព្រៀងភាពជាដៃគូអន្តរប៉ាស៊ីហ្វិក។ លោកប្រធានាធិបតី ចូ បៃដិន បានលើកឡើងថា គោលបំណងនៃក្របខ័ណ្ឌនេះនឹង "កំណត់គោលបំណងរួមរបស់យើង ក្នុងវិស័យកិច្ចសម្រួលពាណិជ្ជកម្មស្តង់ដារសម្រាប់សេដ្ឋកិច្ចនិងបច្ចេកវិទ្យាឌីជីថល ភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់ ការកាត់បន្ថយឧស្ម័នកាបូនិក និងថាមពលស្អាត ហេដ្ឋារចនាសម្ព័ន្ធ ស្តង់ដារការងារ និងវិស័យផ្សេងទៀតដែលបម្រើផលប្រយោជន៍រួម"។ ចុចទីនេះដើម្បីអានបន្ថែម

## វិធីប្រាំយ៉ាងដែលវិបត្តិអ៊ុយក្រែន បង្កផលប៉ះពាល់ដល់ទីផ្សារសកល និងពាណិជ្ជកម្មអន្តរជាតិ

ប្រភព៖ វិទ្យាស្ថានសម្រាប់ការនាំចេញ និងពាណិជ្ជកម្មអន្តរជាតិ

លោក វ្លាឌីមៀ ពូទីន កាលពីថ្ងៃទី ២២ ខែកុម្ភៈ បានធ្វើឱ្យវិបត្តិអ៊ុយក្រែនកាន់តែដុនដាបជាងមុន ក្រោយពីលោកបានស្នើសុំ (និងទទួលបាន) ការអនុញ្ញាតពីសមាជិកសភារុស្ស៊ី ដើម្បីដាក់ពង្រាយកងកម្លាំងរុស្ស៊ីនៅប្រទេសនេះ។ វិបត្តិនេះអាចបង្ករផលប៉ះពាល់លើពាណិជ្ជកម្មអន្តរជាតិ ជាប្រាំរូបភាព។ (១) រុស្ស៊ីប្រឈមនឹងទណ្ឌកម្ម ខណៈសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងសហភាពអឺរ៉ុបទើបតែបានប្រកាសអំពីកញ្ចប់ទណ្ឌកម្មរៀងៗខ្លួន ដែលភាគច្រើនដាក់លើស្ថាប័នហិរញ្ញវត្ថុរបស់រុស្ស៊ី។ (២) តម្លៃប្រេងនឹងកើនឡើង តួយ៉ាងក្រុមហ៊ុន UK Motorist Group រំពឹងថាតម្លៃប្រេងឥន្ធនៈនឹងកើនឡើងលើសពី ១,៥០ ផោន ក្នុងមួយលីត្រ ក្នុងរយៈពេលប៉ុន្មានថ្ងៃខាងមុខនេះ។ (៣) តម្លៃអាហារនឹងកើនខ្ពស់ជាងមុន ដោយសាររុស្ស៊ីជាអ្នកផ្គត់ផ្គង់ស្រូវសាលីធំជាងគេបំផុតរបស់ពិភពលោក ខណៈប្រទេសអ៊ុយក្រែនជាអ្នកនាំចេញដ៏សំខាន់នូវគ្រាប់ធញ្ញជាតិ និងសាច់មាន់។ (៤) ទីផ្សារភាគហ៊ុននឹងធ្លាក់ចុះ តួយ៉ាង The Financial Times Stock Exchange នៅទីក្រុងឡុងដ៍ និង Dow Jones នៅទីក្រុងញូវយ៉ក ក៏បានធ្លាក់ចុះ។ (៥) ក្រុមហ៊ុនលោកខាងលិចនៅក្នុងប្រទេសរុស្ស៊ី នឹងរងការស្ទះដំណើរការ ដោយសារតែក្រុមហ៊ុនទាំងនោះមួយចំនួនមានទ្រព្យសម្បត្តិ ឬការបណ្តាក់ទុនរបស់រុស្ស៊ី ក្នុងនោះរួមមានក្រុមហ៊ុន Shell, BP, Renault, Carlsberg និងធនាគារផ្សេងទៀត។ ចុចទីនេះដើម្បីអានបន្ថែម

## ប្រាំឆ្នាំក្រោយកិច្ចព្រមព្រៀងកិច្ចសម្រួលពាណិជ្ជកម្មចូលជាធរមាន ខ្សែច្រវាក់ផ្គត់ផ្គង់នៅតែមានភាពធន់

ប្រភព៖ អង្គការពាណិជ្ជកម្មពិភពលោក

លោកជំទាវ Okonjo-Iweala អគ្គនាយិកាអង្គការ WTO បានមានប្រសាសន៍ថា កិច្ចខិតខំប្រឹងប្រែងរបស់សមាជិកអង្គការនេះក្នុងការអនុវត្តកិច្ចព្រមព្រៀងកិច្ចសម្រួលពាណិជ្ជកម្ម (TFA) ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ គឺមានសារៈសំខាន់ណាស់សម្រាប់ធានាភាពធន់ នៃខ្សែច្រវាក់ផ្គត់ផ្គង់សកល ចំពេលដែលពិភពលោកកំពុងប្រឹងស្តារសេដ្ឋកិច្ចពីជំងឺរាតត្បាតកូវីដ-១៩។ គិតត្រឹមថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ ការជូនដំណឹង ដោយសមាជិកអង្គការ WTO បានបង្ហាញថា នាពេលបច្ចុប្បន្ននេះ សមាជិកអង្គការនេះបានប្តេជ្ញាអនុវត្តបានប្រមាណ ៧៤,៣% នៃកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ ។ TFA គឺជាកិច្ចព្រមព្រៀងទីមួយរបស់អង្គការ WTO ដែលសមាជិកកំពុងអភិវឌ្ឍន៍ និងអភិវឌ្ឍន៍តិចតួច អាចកំណត់កាលវិភាគនៃការអនុវត្តផ្ទាល់របស់ពួកគេ និងការទទួលបានការពង្រឹងសមត្ថភាពអនុវត្តកាតព្វកិច្ច តាមរយៈការផ្តល់ជំនួយ និងការគាំទ្រនានា ផ្តល់ក្រោមកិច្ចព្រមព្រៀងនេះ។ ចុចទីនេះដើម្បីអានបន្ថែម

## ការចរចាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅតែបន្ត ខណៈសមាជិកអំពាវនាវឱ្យមានការខិតខំប្រឹងប្រែងកាន់តែខ្លាំងនៅឆ្នាំ២០២២

ប្រភព៖ អង្គការពាណិជ្ជកម្មពិភពលោក

អូស្ត្រាលី ជប៉ុន និងសិង្ហបុរី ដែលជាសហភាគីសម្របសម្រួលនៃការចរចាលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បានជំរុញឱ្យសមាជិកបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេនៅឆ្នាំ២០២២ ដើម្បីទទួលបានជំហររួមលើបញ្ហាជាច្រើននៅក្នុងការចរចា។ ឯកអគ្គរាជទូតជប៉ុន កាហ្សូយូគិ យ៉ាម៉ាហ្សាគិ បានរំលឹកឡើងវិញនូវសេចក្តីថ្លែងការណ៍រួម ដែលបានចេញកាលពីខែធ្នូ ឆ្នាំ២០២១ ដែលក្នុងនោះ រដ្ឋមន្ត្រីអូស្ត្រាលី ជប៉ុន និងសិង្ហបុរីបានស្វាគមន៍ចំពោះវឌ្ឍនភាពក្នុងការចរចា និងកំណត់គោលដៅសម្រាប់សមាជិក។ ឯកអគ្គរដ្ឋទូតសិង្ហបុរី ហ៊ុង សេងតាន់ បានមានប្រសាសន៍ថា សមាជិកគួរតែបន្តការងារល្អនៅក្នុងក្រុមតូចៗ និងពន្លឿនការសម្រួលបទប្បញ្ញត្តិទាក់ទងនឹងនីតិវិធីចេញវិក្កយបត្រអេឡិចត្រូនិក និងប្រតិបត្តិការអេឡិចត្រូនិក។ ចុចទីនេះដើម្បីអានបន្ថែម

## ប្រទេសមានតម្រូវការប្រេងខ្ពស់កំពុងព្រួយបារម្ភពីភាពអាចកើតឡើងនៃការដាក់ទណ្ឌកម្មលើប្រទេសរុស្ស៊ី

ប្រភព៖ Bloomberg

ក្រុមហ៊ុននាំចូលប្រេងកំពុងដុតដៃដុតជើងក្នុងការវាយតម្លៃហានិភ័យនៃការទិញប្រេងពីក្រុមហ៊ុនផ្គត់ផ្គង់របស់រុស្ស៊ី ខណៈវិបត្តិអ៊ុយក្រែនកំពុងមានភាពតានតឹង។ ពាណិជ្ជករ និងអ្នកទិញប្រេងមកពីរុស្ស៊ី ដែលបំពេញតម្រូវការខ្លាំងនៅតំបន់អាស៊ី កំពុងមានការព្រួយបារម្ភពីការរឹតត្បិតពាណិជ្ជកម្មប្រេង ប្រសិនបើប្រទេសរុស្ស៊ីដែលជាសមាជិក OPEC+ ត្រូវបានរងទណ្ឌកម្មណាមួយ។ អ្នកបញ្ជាទិញជាច្រើននៅអឺរ៉ុបបាននិយាយថា ពួកគេកំពុងតែរង់ចាំមើលផលប៉ះពាល់ពីវិបត្តិអ៊ុយក្រែននេះ។ ប្រេងចេញពីប្រទេសអារ៉ាប៊ីសាអូឌីត និងទីក្រុងអាប៊ូដាប៊ី នឹងក្លាយជាអ្នកទទួលផលចេញពីវិបត្តិនេះ ប្រសិនបើតំបន់អាស៊ីលែងប្រើប្រាស់ប្រេង ដែលផលិតដោយក្រុមហ៊ុន Sokol និង ESPO របស់រុស្ស៊ី។ ចុចទីនេះដើម្បីអានបន្ថែម

## GLOBAL NEWS BRIEF

### WTO Sides with China in US Tariff Fight

Source: The Wall Street Journal

The World Trade Organization authorized China to impose retaliatory tariffs worth $645 million on imports from the US in a dispute over Chinese subsidies to promote exports of products such as solar panels and steel pipes. Adam Hodge, a spokesman for the US Trade Representative's Office, blasted the decision, saying the WTO protects "China's non-market economic practices and undermines the fair, market-oriented competition." Chad Bown, a senior fellow at Peterson Institute for International Economics, said that if China chooses to implement the retaliatory tariffs authorized by the WTO, it would risk "reinitiating a tariff escalation of the US-China trade war, that is now in a fragile state of truce." The US and other free-market nations have complained that Beijing gives unfair advantages to Chinese manufacturers over companies from their nations. The latest decision favoring China is "one more motivation for why the US, China, EU and other major WTO members need to figure out new rules [on] countervailing duties," said Mr. Bown. Click here to read more

### Vaccine Advocacy Groups Press Biden to Break WTO Deadlock

Source Politico

In a letter addressed to President Joe Biden, vaccine advocacy groups, including Oxfam America, are pressing the President to help break a deadlock at the WTO by embracing South Africa and India's demand for a broad waiver of intellectual property right protections to fight Covid-19. The US since May 2021 endorsed support of such proposal for waiver of intellectual property rights just for vaccines. Yet, the EU continues to resist the proposal, arguing that current WTO rules already allow countries to waive IP protections in health emergencies. Pharmaceutical companies also oppose the waiver request, arguing that such request would undermine the financial incentives that encourage them to invest heavily in the development of life-saving drugs. Click here to read more

### US Moves toward New 'Framework' for Trade with Indo-Pacific Region

Source: VOA

The new US administration is expected to launch the Indo-Pacific Economic Framework to reinstate the US as a counterweight to China and as a major player in developing trade rules that govern the region. US business and trade groups have been anxious for the administration to establish itself as a presence in the region after the then Trump administration had formally removed the US from the Trans-Pacific Partnership. President Joe Biden said the objective of the framework would be to "define our shared objectives around trade facilitation, standards for the digital economy and technology, supply chain resiliency, decarbonization and clean energy, infrastructure, worker standards, and other areas of shared interest." Click here to read more

### Five Ways the Ukraine Crisis is Impacting Global Markets and International Trade

Source: Institute of Export and International Trade

Vladimir Putin on 22 February further escalated the crisis in Ukraine by requesting (and gaining) authorization from Russian legislators to deploy forces abroad. There are five possible impacts derived from the crisis on international trade. First, Russia will be facing sanctions, as the US, UK, and EU have just announced their respective packages of sanctions, mostly on financial institutions. Second, oil price will rise, as the UK Motorist Group expected fuel prices to rise above £1.50 per litre soon. Third, food prices will be higher, as Russia is the world's largest supplier of wheat, while Ukraine is a main exporter of grain and chicken. Fourth, stock market will plunge, as the Financial Times Stock Exchange in London and Dow Jones in New York have also declined. Lastly, western firms in Russia will be down, especially those with Russian assets or ventures, including Shell, BP,

Renault, Carlsberg, and various banks. [Click here to read more]

### Supply Chain Resilience Highlighted at Fifth Anniversary of Trade Facilitation Agreement

Source: World Trade Organization

"WTO members' efforts to implement the Trade Facilitation Agreement over the past five years have been vital for global supply chain resilience, which is more than ever important amid the demands for a sustainable recovery from the pandemic," DG Okonjo-Iweala said. As of 22 February 2022, notifications submitted by WTO members indicate that they have committed to implement 74.3% of TFA obligations at present. The TFA is the first WTO agreement in which developing and LDC members can determine their own implementation schedules and seek to acquire implementation capacity through the provision of related assistance and support. Click here to read more

### E-Commerce Negotiations Resume with Call for Intensified Efforts in 2022

Source: World Trade Organization

The co-convenors of the negotiations on e-commerce, Australia, Japan and Singapore, urged members to intensify their efforts in 2022 to secure convergence on the majority of issues in the negotiations. Ambassador Kazuyuki Yamazaki (Japan), recalled the joint statement issued in December 2021, in which the ministers of Australia, Japan and Singapore welcomed the progress in the negotiations and set a goal for members. Ambassador Hung Seng Tan (Singapore) said that members should keep up the good work in the small groups and build momentum to clean up provisions such as e-invoicing and electronic transactions frameworks. Click here to read more

### Oil-Hungry Buyers Reel from Prospect of Russia Sanctions

Source: Bloomberg

Oil importers are racing to assess the risk of purchasing Russian supplies as tensions over Ukraine are being intensified. Traders and buyers of Asia's favored oil grades from Russia are becoming increasingly wary of being caught up in possible trade restrictions should the OPEC+ producer be sanctioned. Several buyers in Europe said they are still waiting to see the full impact of the Ukraine situation. Crude from Saudi Arabia and Abu Dhabi will be the possible beneficiaries should Asia ignore Sokol and ESPO. Click here to read more

# អត្ថបទទស្សនៈ៖ តើជាតុសំខាន់ៗអ្វីខ្លះគួរតែត្រូវបានពិចារណាពេលធ្វើសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការ?

ដោយ៖ លោក កែវ ប៊ុនថេង
ប្រធានការិយាល័យច្បាប់ពាណិជ្ជកម្ម
នាយកដ្ឋាននីតិកម្ម
ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២

មជ្ឈត្តការ ជាប្រព័ន្ធដោះស្រាយវិវាទផ្លូវការមួយ ដែលគូភាគីនៃវិវាទ ផ្អែកលើគោលការណ៍ព្រមព្រៀងគ្នា បញ្ជូនករណីវិវាទរបស់ខ្លួន មកកាន់វេទិកាមជ្ឈត្តកម្ម ដើម្បីផ្តល់ដំណោះស្រាយដែលមានអានុភាពគតិយុត្តិ។ ដំណើរការមជ្ឈត្តការមានលក្ខណៈឯកជន រក្សាការសម្ងាត់ ឆាប់រហ័ស និងទទួលបានដំណោះស្រាយដែលអាចអនុវត្តបាន ព្រមទាំងចំណាយថវិកាតិច។ ចំណុចសំខាន់មួយចំនួន គួរត្រូវបានពិចារណាយ៉ាងល្អិតល្អន់ នៅពេលរៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការ។

**ចំណុចដំបូង** ដែលត្រូវពិចារណាគឺ ការរក្សាសម្ងាត់របស់គូភាគីវិវាទ។ ទោះបីជាគោលការណ៍រក្សាការសម្ងាត់ជាអត្ថប្រយោជន៍ទទួលបានពីដំណើរការមជ្ឈត្តការក្តី ក៏ការរក្សាការសម្ងាត់នៅតែមិនអាចធានាបាន ដរាបណាមិនមានការយល់ព្រមទទួលស្គាល់ពីគូភាគីវិវាទ។ វិធានមជ្ឈត្តការភាគច្រើនគ្រាន់តែតម្រូវឱ្យស្ថាប័ន និងវេទិកាមជ្ឈត្តកម្ម រក្សាការសម្ងាត់នូវរាល់ដំណើរការនៃការជម្រះក្តី ប៉ុន្តែមិនបានដាក់កាតព្វកិច្ចដូចគ្នានេះ ដល់គូភាគីវិវាទនោះទេ។ ដូច្នេះ ករណីដែលគូភាគីវិវាទទាមទារឱ្យរក្សាការសម្ងាត់ ពួកគេគួរបញ្ជាក់ឱ្យបានច្បាស់លាស់ពីចំណុចនេះនៅក្នុងកិច្ចព្រមព្រៀង នៃដំណើរការដោះស្រាយវិវាទ លើកលែងតែចំណុចណាផ្សេងតម្រូវដោយច្បាប់។

**ចំណុចទី២** វិសាលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពិតជាមានសារសំខាន់ណាស់។ វិសាលភាពនេះនឹងកំណត់អំពីប្រភេទនៃវិវាទ ដែលអាចដាក់ឱ្យដោះស្រាយតាមយន្តការមជ្ឈត្តការ។ ភាពមិនច្បាស់លាស់នៃវិសាលភាពនៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការ នឹងនាំឱ្យមានវិវាទលើយុត្តាធិការនៃវេទិកាមជ្ឈត្តកម្ម ដែលប្រការនេះនឹងតម្រូវឱ្យតុលាការ ឬវេទិកាមជ្ឈត្តកម្ម ធ្វើការពិនិត្យ លើបញ្ហាយុត្តាធិការនេះ តាមនីតិវិធីជាធរមាន (អាចចំណាយពេលយូរ និងថវិកាច្រើន) មុននឹងឈានបន្តទៅដោះស្រាយចំណុចសារធាតុក្នុងវិវាទនោះជូនគូភាគី។ នៅក្នុងការអនុវត្តជាក់ស្តែង វិសាលភាពដែលព្រាងឡើងដោយមានលក្ខណៈចង្អៀត និងមិនគ្រប់ជ្រុងជ្រោយនឹងបង្កទៅជាប្រភពនៃវិវាទនានា ហើយធ្វើឱ្យវេទិកាមជ្ឈត្តកម្មបាត់បង់យុត្តាធិការលើករណីវិវាទនេះ ដោយផ្នែក ឬទាំងស្រុង។ ដូច្នេះកិច្ចព្រមព្រៀងមជ្ឈត្តការ គួរកំណត់ឱ្យច្បាស់ពីវិវាទជាក់លាក់ ឬវិវាទទូទៅណាមួយ ដែលកើតចេញពីទំនាក់ទំនងកិច្ចសន្យា ឬទំនាក់ទំនងគតិយុត្តិផ្សេងទៀត ដែលត្រូវដាក់ជូនទៅមជ្ឈត្តការ។ ដើម្បីចៀសវាងភាពអាចកើតឡើងនៃវិវាទកើតចេញពីភាពមិនច្បាស់លាស់ នៃកិច្ចព្រមព្រៀងមជ្ឈត្តការនេះ វាជាការដែលគួរតែពិចារណាក្នុងការកំណត់វិសាលភាពនៃកិច្ចព្រមព្រៀងនេះឱ្យបានទូលំទូលាយ តាមដែលអាចធ្វើទៅបាន។ ក្នុងន័យនេះ កិច្ចព្រមព្រៀងដែលមានលក្ខណៈទូលំទូលាយបង្ការមិនឱ្យមានការបំបែកបន្តនៃវិវាទដើម និងចៀសវាងនូវផលវិបាកផ្សេងៗដែលអាចកើតឡើងនៅពេលដែលកិច្ចសន្យាក្លាយជាមិនមានសុពលភាព។

**ចំណុចទី៣** ដែលត្រូវពិចារណាគឺទីកន្លែងនៃមជ្ឈត្តការ។ ទីកន្លែងនេះសំដៅដល់ ទីកន្លែងផ្លូវច្បាប់ដែលគូភាគីវិវាទបានជ្រើសរើស សម្រាប់ដំណើរការនីតិវិធីមជ្ឈត្តការ ដែលកំណត់អំពីក្របខ័ណ្ឌនីតិវិធី និងវិធានផ្សេងៗដែលគ្រប់គ្រងដំណើរការមជ្ឈត្តការ ក៏ដូចជាសិទ្ធអំណាចរបស់តុលាការដែលអាចជ្រៀតជ្រែកក្នុងដំណើរការមជ្ឈត្តការ។ ឧទាហរណ៍៖ ការដាក់ចេញនូវវិធានការបណ្តោះអាសន្ន ឬការលុបចោលមជ្ឈត្តវិនិច្ឆ័យ។ ដើម្បីចៀសវាងនូវការភ័ន្តច្រឡំ មាត្រា១៨នៃច្បាប់ស្តីពីវិធាននៃមជ្ឈត្តការរបស់សភាពាណិជ្ជកម្មអន្តរជាតិ (ICC Rule ២០១៧) និងមាត្រា១៦ នៃច្បាប់ស្តីពីវិធាននៃមជ្ឈត្តការអន្តរជាតិនៃតុលាការទីក្រុងឡុង (LCIA ២០១៤) បញ្ជាក់ពីភាពខុសគ្នារវាងទីកន្លែង (Place) និងទីតាំងជំនុំជម្រះរបស់មជ្ឈត្តការ (Venue)។ មានន័យថាទីកន្លែងផ្លូវច្បាប់នៃមជ្ឈត្តការ ត្រូវបែងចែកឱ្យដាច់ចេញពីទីកន្លែងរូបវន្តសម្រាប់ដំណើរការជំរះក្តីមជ្ឈត្តការ ទោះបីជាទីកន្លែងផ្លូវច្បាប់ និងទីកន្លែងរូបវន្តស្ថិតក្នុងទីតាំងតែមួយក៏ដោយ។

**ចំណុចទី៤** កិច្ចព្រមព្រៀងមជ្ឈត្តការត្រូវតែបង្ហាញឱ្យច្បាស់លាស់ពីច្បាប់ដែលគ្រប់គ្រង ឬជម្រើសនៃច្បាប់។ ការចែងច្បាស់លាស់ពីវិធានច្បាប់ណាដែលគ្រប់គ្រងវិវាទ ពិតជាមានសារសំខាន់ ដោយសារច្បាប់នេះនឹងគ្រប់គ្រងកម្មវត្ថុនៃវិវាទ និងដំណើរការជម្រះក្តីដែលត្រូវតែគោរពតាម។ ភាគីវិវាទត្រូវតែសម្រេចចិត្តឱ្យបានច្បាស់លាស់ ក្នុងការជ្រើសរើសវិធានច្បាប់ណាមួយ ដែលពួកគេចង់បានសម្រាប់ដោះស្រាយវិវាទដែលកើតឡើង ដែលបន្ទាប់មកទៀត វេទិកាមជ្ឈត្តកម្មនឹងយកច្បាប់នោះមកអនុវត្ត ដោយផ្អែកលើទិដ្ឋភាពនៃវិវាទនោះ។ ប្រសិនបើភាគីវិវាទមិនបានបញ្ជាក់ឱ្យច្បាស់លាស់ទេ វាអាចជាប្រភពដែលបង្កើតឱ្យមានវិវាទបន្ថែមទៀត។

**ចំណុចទី៥** *ត្រូវមានការពិចារណាលើ ជម្រើសនៃវិធាន និងស្ថាប័នមជ្ឈត្តការ។* យោងតាមគោលការណ៍ទូទៅចែងក្នុងច្បាប់ស្តីពីវិធាននៃមជ្ឈត្តការរបស់សភាពាណិជ្ជកម្មអន្តរជាតិ (ICC Rule of Arbitration) វិវាទទាំងអស់ត្រូវតែត្រូវបានដោះស្រាយអនុលោមតាមច្បាប់ដែលបានចូលជាធរមាន ចាប់ពីថ្ងៃដែលដំណើរការមជ្ឈត្តការបានចាប់ផ្តើម លើកលែងតែករណី ដែលភាគីវិវាទយល់ព្រមអនុវត្តវិធានច្បាប់ណាមួយ ដែលបានចូលជាធរមានមុនពេលកិច្ចព្រមព្រៀងមជ្ឈត្តការនោះត្រូវបានបញ្ចប់។ លើសពីនេះ មានមជ្ឈត្តការពីរប្រភេទដែលភាគីវិវាទអាចជ្រើសរើសសម្រាប់ដំណើរការជម្រះក្តី គឺមជ្ឈត្តការអាដហុក (បណ្តោះអាសន្ន) និងមជ្ឈត្តការស្ថាប័ន។ មជ្ឈត្តការស្ថាប័ន ជាមជ្ឈត្តការដែលបង្កើតឡើង និងទទួលស្គាល់ដោយស្ថាប័នមជ្ឈត្តការ ដូចជា ICC, SIAC និង HKIAC ដែលភាគច្រើនស្ថាប័នទាំងនេះមានវិធានច្បាប់ និងបែបបទរដ្ឋបាលសម្រាប់មជ្ឈត្តការ។ ដោយឡែក មជ្ឈត្តការអាដហុក ជាមជ្ឈត្តការដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយស្ថាប័នណាមួយឡើយ និងតម្រូវឱ្យភាគីវិវាទធ្វើការសម្រេចចិត្តដោយខ្លួនឯងក្នុងការជ្រើសរើសវេទិកាមជ្ឈត្តកម្ម។

**ចំណុចសំខាន់ចុងក្រោយ** *គឺការពិចារណាទៅលើ ភាសានៃដំណើរការមជ្ឈត្តការ និងចំនួននៃមជ្ឈត្តករ។* ភាសាដែលត្រូវបានប្រើប្រាស់ក្នុងនីតិវិធីមជ្ឈត្តការ គឺពាក់ព័ន្ធគ្រប់ទិដ្ឋភាពនៃដំណើរការមជ្ឈត្តការ រាប់បញ្ចូលទាំងការទាមទាររបស់ភាគីវិវាទ ឯកសារសម្រាប់ធ្វើបទបង្ហាញ ភស្តុតាង និងមជ្ឈត្តវិនិច្ឆ័យជាដើម។ បញ្ហាភាសានេះ អាចប៉ះពាល់ដល់លទ្ធភាពរបស់គូវិវាទ នៅពេលចូលរួមក្នុងដំណើរការ និងការជ្រើសរើសមជ្ឈត្តករ។ ដូច្នេះហើយ នេះជាចំណុចសំខាន់ដែលគូវិវាទត្រូវសម្រេចចិត្ត ប្រសិនបើពួកគេមិនប្រើភាសាដូចគ្នា។ ក្រៅពីនេះ ការកំណត់ចំនួនមជ្ឈត្តករក៏មានសារសំខាន់ដែរ។ នៅក្នុងការអនុវត្តច្បាប់ជាក់ស្តែង ចំនួនមជ្ឈត្តករ គឺអាស្រ័យលើវិសាលភាព និងភាពស្មុគស្មាញនៃវិវាទ។ ហេតុដូចនេះ នៅពេលធ្វើសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការ ភាគីវិវាទគួរតែព្រាងកិច្ចព្រមព្រៀងមជ្ឈត្តការឱ្យបានហ្មត់ចត់ តាមរយៈការបញ្ជាក់ឱ្យច្បាស់ពីចំនួននៃមជ្ឈត្តករ ព្រោះបើមិនដូច្នេះទេ ស្ថាប័នមជ្ឈត្តកម្ម នឹងធ្វើការសម្រេចលើចំនួនមជ្ឈត្តករ នៅពេលមានវិវាទកើតឡើង។

*© រក្សាសិទ្ធិដោយវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ។ ខ្លឹមសារនៃអត្ថបទនេះជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ក្រសួងពាណិជ្ជកម្ម និងស្ថាប័នពាក់ព័ន្ធឡើយ៕*

## OPINION ARTICLE

# What are the Necessary Elements to be Considered When Drafting an Arbitration Clause?

Mr. KEO Buntheng
Chief of Commercial Law Bureau
Department of Legal Affairs
17 February 2022

Arbitration is a system of formal dispute resolution in which a dispute is submitted, by agreement of the parties, to arbitral tribunal to make a binding decision on the dispute. Arbitration is a private and, to a greater or lesser degree, confidential process and can provide the quick, practical and economical settlement of disputes. There are some main points to be considered and taken into account when drafting an arbitration clause.

**First of all,** the consideration that the parties must take into account is 'confidentiality'. Even though the confidentiality is recognized as a benefit of arbitration, confidentiality is not guaranteed unless the parties expressly provide for it. Most arbitral rules only require the institutions and tribunal to maintain the confidentiality of the proceedings, and do not impose the same obligation on the parties. Thus, if parties desire confidentiality, they should specify so in the dispute resolution clause, except where disclosure may be required by law.

**Second,** the scope of arbitration agreements is very important. The scope will set out the types of disputes that can be referred to arbitration. Uncertainties regarding the scope of the arbitration clause often lead to disputes concerning the jurisdiction of the arbitral tribunal which in turn will make it necessary for the court or the arbitral tribunal to conduct (costly and time consuming) procedural steps to clarify the issue of jurisdiction, before dealing with the substantive claims (Welser & Molitoris, 2012). In practice, a poorly and narrowly drafted scope is a common source of disputes and may deprive the tribunal of jurisdiction over all or parts of the dispute. Therefore, arbitration clauses may refer either specific, or general disputes, arising out of a contractual or other legal relationship, to arbitration. To limit possible conflicts as to whether a matter falls under the arbitration clause, it is deemed advisable to draw such clauses as widely as possible . In this regard, it is claimed that broad arbitration clauses may prevent the fragmentation of disputes and avoid additional complications arising when the underlying contract itself turns out to be invalid.

**Third,** the consideration shall be made on 'seat of arbitration'. The seat of arbitration is a location selected by the parties as the legal place of arbitration, which consequently determines the procedural framework and rules that govern the arbitration, as well as the court that has the power to interfere in arbitration proceedings, i.e. the issuance of interim measures or the annulling of an award. To avoid confusion, Article 18 of the ICC Rules (2017) and Article 16 of the LCIA Rules (2014) emphasize the difference between the place and the venue. Therefore, the seat of arbitration must be distinguished from the physical place where hearings are to be conducted, even though they usually are at the same location.

**Fourth,** the arbitration clause shall clearly indicate 'governing law' or 'choices of law'. Determining clearly the governing law is another important consideration as it will govern the subject of the disputes and what proceedings are to be followed. Based on this, the parties must clearly decide on the law they wish to apply to any disputes that arise, then that tribunal will apply that law to the merits of the dispute. If this is not specified, it may be a source of substantial dispute in itself.

**Fifth,** the consideration must be made on 'choice of arbitral rules and institutions'. According to the general principles outlined in the ICC Rules of Arbitration (ICC Rules of Arbitration), all disputes shall be settled in accordance with the rules as in force on the date arbitration proceedings commenced, unless the parties agreed to apply the rules as in force prior to conclusion of the arbitration agreement. In addition, there are two types of arbitration that parties can choose to resolve disputes, either institutional or ad hoc. The institutional arbitration is an arbitration that is administered by a recognized arbitral institution, such as ICC, SIAC, HKIAC, and mostly those institutions have their own rules and administrative procedures for the arbitration. However, ad hoc arbitration is an arbitration that is not administered by an institution and requires the parties to make their own arrangements for the selection of the arbitral tribunal.

**Last but not least,** other considerations shall be made on 'language of arbitration' and 'number of arbitrators'. The language of the arbitration is relevant to all aspects of the proceeding including the parties' pleadings, the presentation of documentary, evidence, and the award. Also, it affects clients' ability to participate and choice of arbitrators. Therefore, this is an important aspect to determine, particularly when the parties do not have a common language. Besides, the number of arbitrators is also significant. In legal practice, the number of arbitrators depends on the amount in dispute and the complexity of the case. Hence, when drafting the contracts, parties should carefully draft an arbitration clause by clearly indicating the number of arbitrators; otherwise, it will be decided by the arbitral institution once the dispute arises.

*© All use subject to TTRI. The views expressed here are those of the author and do not reflect that of the Ministry of Commerce and their affiliated organizations.*

# About the i-Trade Bulletin

iTrade Bulletin is an e-publication by the Trade Training and Research Institute of the Ministry of Commerce. This monthly bulletin provides brief updates on specific issues in Cambodia, the regions and the world. This knowledge-sharing through scientific researches in the multifaceted areas aims to highlight current trade news & statistics relevant to all social stakeholders.

**Honorable President**
H.E. Mr. PAN Sorasak

**Editorial Board**
- H.E. Mrs. CHAM Nimul (Chairwoman)
- H.E. Ms. SEREI Borapich
- Mr. HOR Iengchhay
- Mr. SOK Bunthorn

**Advisors**
- H.E. Mr. SIM Sokkheng
- H.E. Mr. PENN Sovicheat
- H.E. Dr. TAT Puthsodary
- H.E. Prof. Shandre Mugan THANGAVELU

**People behind iTrade Bulletin**
- Mr. PAO Phireak
- Mr. CHINKET Tola
- Ms. YANGNY Chakriya
- Ms. CHEA Kunlak
- Ms. PHAL Yita
- Mr. LY Rithy
- Mr. SE Sokunvathna
- Mr. NY Atykunn

## Annoucement

Academicians, researchers, students and public are welcome to contribute their academic works, on all disciplines and topics of relevant interest to trade, to the next publication of the iTrade Bulletin.

### Topics Covered:

- Domestic and International Trade
- Domestic and International Economics
- 4th Industrial Revolution (4IR) and Technology
- Social Issue
- Gender Equality
- Other relevant topics.

### Categories:

- Research articles
- Case reports
- Policy Briefs
- Commentaries or editorial

For more information, please scan

វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ - TTRI
https://ttri.info/
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA